# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាជាមួយមណ្ឌលនិស្សិតនៅភ្នំវល្លិ៍
# ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨
## *ព្រះជាម្ចាស់ចង់ឲ្យយើងមានសេចក្ដីសុខ*

អត្ថបទទី១៖ យរ ៣១,៧-៩
អត្ថបទទី២៖ ហាប ៥,១-៦
ដំណឹងល្អ៖ មក ១០,៤៦-៥២

បងប្អូនជាទីស្រឡាញ់!

នៅភ្នំវល្លិ៍នេះ មានចម្ការស្វាយមួយ ពីឆ្នាំ២០០៣ រហូតដល់ពេលនេះអត់ទាន់មានផ្លែមួយទេ។ ម្ចាស់ចំការខិតខំដាក់ឃ្មុំ ដើម្បីឲ្យវាយកលំអងផ្កា បាញ់អរម៉ូនក៏មិនជោគជ័យ។ នៅក្នុងចិត្តខ្ញុំរហូតដល់ថ្ងៃនេះ ខ្ញុំសួរខ្លួនឯងថា មូលហេតុអីគាត់មិនកាប់ចោល។ ប្រហែលគាត់ស្ដាប់ព្រះយេស៊ូជាពាក្យប្រស្នាដែលយើងស្ដាប់ថ្ងៃនេះ។ នៅពេលអត់មានផ្លែ ឆ្នាំទី១ទុកសិន ធ្វើដី ស្រោចទឹក ថែរក្សា ហើយចាំមួយឆ្នាំទៀត។ មនុស្សយើងត្រូវប្រយ័ត្ន ប្រសិនបើយើងរៀបការហើយអត់ត្រូវគ្នា អត់ចេញផ្កាអត់ចេញផ្លែដែរ។ ប៉ុន្តែដើមស្វាយយើងនៅទីនេះខ្ញុំអត់កាប់ទេ ខ្ញុំទុកដោយសារមានម្លប់ត្រជាក់ និងទុកសម្រាប់ថ្វាយអភិបូជានៅទីនេះ។

នៅពេលយើងមកដល់ភ្នំវល្លិ៍ នៅពេលយើងឡើងភ្នំ នៅពេលយើងផុតភ្នំហើយ យើងមើលឃើញចម្ការស្វាយ ចំការធូរ៉េន ភ្នំ យើងមានអារម្មណ៍ថាយើងមើលឃើញមហាសមុទ្រពីចម្ងាយ ហើយនៅពេលនោះបីដូចជាយើងយល់ អំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ការអស្ចារ្យកាលព្រះជាម្ចាស់បង្កើតពិភពលោកពីដើម ឲ្យមនុស្សមានសេចក្ដីសុខសាន្ត ដោយសារព្រះជាម្ចាស់ចង់ឲ្យយើងមានសេចក្ដីសុខ។ នៅពេលដែលយើងស្ដាប់គម្ពីរថ្ងៃនេះយើងយល់ទៀត ព្រះយេស៊ូមិនចង់ឲ្យយើងដាច់ខ្យល់ មិនចង់ឲ្យយើងស្លាប់ភ្លាមៗ ព្រះយេស៊ូមានបន្ទូលថា «**កែប្រែចិត្តគំនិតទៅ ទុកឱកាសឲ្យមានសេចក្ដីសុខដែលពេញលក្ខណៈ**»។ មុនដំបូងមនុស្សមានសេចក្ដីសុខដោយមកមានអាដាំអេវ៉ានៅក្នុងសួនអេដែន ដូចនៅទីនេះ គេឃើញផ្លែឈើមួយល្អណាស់។ តាមពិតដើមឈើមានច្រើន ហើយគេញ៉ាំផ្លែឈើណាក៏បាន លើកលែងតែផ្លែឈើដែលណែនាំឲ្យគេយល់អំពីអ្វីដែលល្អនិងអាក្រក់។ ដោយសារពីសម័យដើម ព្រះជាម្ចាស់បានបង្កើតយើងឲ្យមើលឃើញអ្វីដែលល្អ ពេលគេបេះនិងញ៉ាំផ្លែនេះ នៅពេលនោះ គេមានអារម្មណ៍ថាគេនៅខ្លួនទទេដោយសារគេឃើញអំពើបាប។ ដោយសារភ្នែករបស់គេមើលឃើញអ្វីដែលជាអំពើអាក្រក់ ហើយយើងត្រូវប្រើសេរីភាពរបស់យើងពីថ្ងៃមួយទៅថ្ងៃមួយ ដើម្បីសម្រេចចិត្ត **តើខ្ញុំដើរតាមផ្លូវណា ផ្លូវល្អ ឬអាក្រក់?** យើងចាញ់ការល្បួងប៉ុន្មានលើកប៉ុន្មានសារ និងណែនាំឲ្យយើងខុសផ្លូវទៀត។

ព្រះយេស៊ូមានព្រះបន្ទូលថា **ចូរកែប្រែចិត្តគំនិត** ដោយថែរក្សានូវអ្វីដែលយើងស្តាប់នៅក្នុងអត្ថបទទី១ ជាពិសេសសម្រាប់និស្សិតទាំងអស់ដែលចូលនៅក្នុងឆ្នាំសិក្សាថ្មី។ **តើខ្ញុំបានទទួលទេពកោសល្យ សមត្ថភាពអ្វីខ្លះ ដើម្បីរៀបចំអនាគតរបស់ខ្ញុំ? តើព្រះជាម្ចាស់បានប្រទានអ្វីខ្លះ ដើម្បីឲ្យខ្ញុំទទួលសេចក្តីសុខសាន្តនៅថ្ងៃអនាគត មានគ្រួសារដ៏សុខសាន្ត ការងារដ៏សុខសាន្ត ជីវិតដ៏សុខសាន្ត ដើម្បីណែនាំឲ្យសង្គមរបស់ខ្ញុំទទួលសេចក្តីសុខសាន្ត?** ជាពិសេសនិស្សិតឆ្នាំទី១ សូមពិចារណា **តើខ្ញុំជានរណា? តើព្រះជាម្ចាស់ប្រទានអំណោយទានអីខ្លះឲ្យខ្ញុំ?** ដូចយើងបានស្តាប់ មានខ្លះគេគ្រូអប់រំជំនឿ មានខ្លះគេជាអ្នកដឹកនាំ មានខ្លះគេអាចរៀបចំធម៌មេត្តាករុណា។ ជីវិតរបស់ខ្ញុំជាជីវិតពិសេស ហើយព្រះជាម្ចាស់មានគម្រោងការដ៏អស្ចារ្យសម្រាប់ខ្ញុំ។

ពេលយើងមកដល់ទីនេះ យើងអាចនឹកឃើញពីសម័យដើម សេចក្តីសុខសាន្តដែលព្រះជាម្ចាស់បានរៀបចំ យើងនឹកឃើញសួនច្បារអេដែនពីដើម ដែលព្រះជាម្ចាស់បានរៀបឲ្យមនុស្សមានសេចក្តីសុខ។ សេចក្តីសុខនេះ ទោះបីជួនកាលយើងបាត់បង់ យើងស្តាប់ព្រះបន្ទូលព្រះជាម្ចាស់មានព្រះហឫទ័យអត់ធ្មត់ ដើម្បីទុកពេលវេលាឲ្យយើងបន្តកែប្រែចិត្តគំនិត។ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់គ្រប់អ្វីៗទាំងអស់ដែលព្រះអង្គប្រទាន ដោយដឹងថាព្រះអង្គណែនាំឲ្យយើងរស់នៅក្នុងសេចក្តីសុខ និងសុភមង្គល។ អាម៉ែន៕